**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**
លេខ ៣៤៣១/១៨ សជណ

ថ្ងៃ ច័ន្ទ ៤ រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
កំពង់ធំ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី ការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៨

**យោង៖** ប្រកាសលេខ ៤១០៧,៤១០៨ ប្រក ចុះថ្ងៃអង្គារ ៥កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិ ស័ក ព.ស.២៥៦២ ត្រូវថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០១៨។

រដ្ឋបាលខេត្តកំពង់ធំសូមជូនដំណឹងដល់សិស្ស និស្សិត ដែលមានបំណងចង់ចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារឱ្យបានជ្រាបថា៖ ក្រសួងមហាផ្ទៃសម្រេចបើកឱ្យមានការប្រឡងប្រជែងជ្រើសរើស សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ ២០១៨ ចំនួន ១២ នាក់ សម្រាប់ខេត្តកំពង់ធំ និងខេត្តសៀមរាប ដូចខាងក្រោម៖

១-ពន្ធនាគារខេត្តកំពង់ធំ (មន្ត្រីប្រតិបត្តិ និងមន្ត្រីជំនាញឯកទេស)៖

- -មន្ត្រីប្រតិបត្តិចំនួន ០៩នាក់
- -ពេទ្យមធ្យម ចំនួន ០១នាក់

២-ពន្ធនាគារខេត្តសៀមរាប(មន្ត្រីជំនាញឯកទេស)៖

- -វេជ្ជបណ្ឌិត ចំនួន ០១នាក់
- -ពេទ្យមធ្យម ចំនួន ០១នាក់

**ក-លក្ខខណ្ឌនៃការជ្រើសរើស**

**ក.១- មន្ត្រីប្រតិបត្តិនៅពន្ធនាគារ**

-មានសញ្ជាតិខ្មែរ

-មានកាយសម្បទាគ្រប់គ្រាន់មានសុខភាពល្អ។ បេក្ខជនត្រូវមានកម្ពស់ចាប់ពី សម្រាប់បុរស ១.៦៥ម ឡើង

-មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ

-បេក្ខជនត្រូវមានសញ្ញាបត្រយ៉ាងទាបបំផុតមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល

-ត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ។ ការកម្រិតអាយុត្រូវបានរំកិលពី ២៥ឆ្នាំ ដល់ ៣៥ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល និង៤០ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល។ បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

Scanned by CamScanner

**ក.២- មន្ត្រីជំនាញឯកទេស( ពេទ្យមធ្យម និងវេជ្ជបណ្ឌិត )**

-មានសញ្ជាតិខ្មែរ

-មានកាយសម្បទាគ្រប់គ្រាន់មានសុខភាពល្អ

-មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ

-ត្រូវមានអាយុយ៉ាងតិច ១៨ឆ្នាំហើយមិនលើសពី ២៥ឆ្នាំ។ ការកម្រិតអាយុត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣៥ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល និង ៤០ ឆ្នាំចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល។ បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែង លក្ខខណ្ឌអាយុ។ សម្រាប់បេក្ខជនជំនាញឯកទេសវេជ្ជបណ្ឌិត និងពេទ្យមធ្យមដែលមានសញ្ញាបត្រវេជ្ជបណ្ឌិត និងពេទ្យមធ្យមត្រូវបានលើកលែងលក្ខខណ្ឌអាយុសម្រាប់ការប្រឡងចូលរួមជ្រើសរើស

-បេក្ខជនទាំងពីរភេទត្រូវមានសញ្ញាបត្រតាមមុខជំនាញឯកទេសនីមួយៗ ដូចខាងក្រោម៖

- **វេជ្ជបណ្ឌិត៖**ចាប់ពីសញ្ញាបត្រវេជ្ជបណ្ឌិត ឬសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រឡើងទៅ
- **ពេទ្យមធ្យម៖**ចាប់ពីសញ្ញាបត្រពេទ្យមធ្យម ឬសញ្ញាបត្រគិលានុបដ្ឋាកមធ្យមឡើងទៅ

-បេក្ខជនដែលមានបទពិសោធន៍ការងារពាក់ព័ន្ធ នឹងជំនាញដែលបានជ្រើសរើស(ដោយមានឯកសារបញ្ជាក់) ត្រូវបានលើកទឹកចិត្ត និងផ្តល់អាទិភាព។

**ខ-សំណុំលិខិតដែលត្រូវបំពេញរួមមាន៖**

-ពាក្យសុំចុះឈ្មោះប្រឡង..........ចំនួន ០១ច្បាប់

-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដោយមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការ..........ចំនួន ០១ច្បាប់

-សញ្ញាបត្របរិញ្ញាបត្រនិងឬបរិញ្ញាបត្រជាន់ខ្ពស់ដោយមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការ..........ចំនួន០១ច្បាប់

-ជីវប្រវត្តិមានបិទរូបថត ៤ x ៦..........ចំនួន ០១ច្បាប់

-កិច្ចសន្យា..........ចំនួន ០១ច្បាប់

-រូបថត ៤ x ៦..........ចំនួន ០៣សន្លឹក

-បង្កាន់ដៃទទួលពាក្យប្រឡង..........ចំនួន ០១ច្បាប់

-សលាកប័ត្រឯកត្តជន..........ចំនួន ០១ច្បាប់

-សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត..........ចំនួន ០១ច្បាប់

-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ(ច្បាប់ថតចម្លង)..........ចំនួន ០១ច្បាប់

-លិខិតបញ្ជាក់កិរិយាមាយាទរបស់សាមីខ្លួនចេញដោយអាជ្ញាធរមូលដ្ឋាន..........ចំនួន ០១ច្បាប់

-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ..........ចំនួន ០១ច្បាប់

**គ-វិញ្ញាសា និងថេរវេលានៃការប្រឡងជ្រើសរើស**

**គ.១-មន្ត្រីប្រតិបត្តិនៅធនាគារ ៖**

-ចំណេះដឹងលើវិស័យធនាគារ ចំណេះដឹងទូទៅ និងគណិតវិទ្យា រយៈពេល ០១ ម៉ោង ៣០នាទី (កម្មវិធីសិក្សាថ្នាក់ទី១០ ដល់ ថ្នាក់ទី១២)

-តែងសេចក្តី ឬការសរសេរលិខិតរដ្ឋបាល រយៈពេល ០១ម៉ោង ៣០នាទី (តែងសេចក្តី : កម្មវិធីសិក្សាថ្នាក់ទី១០ដល់ ថ្នាក់ទី១២)

Scanned by CamScanner

**គ.២-ក្របខ័ណ្ឌមន្ត្រីពន្ធនាគារ (ពេទ្យមធ្យម និងវេជ្ជបណ្ឌិត)៖**

សំណុំពាក្យសុំប្រឡងរបស់បេក្ខជននីមួយៗត្រូវឆ្លងកាត់ការពិនិត្យ និងវាយតម្លៃលើសញ្ញាបត្រ និងបទពិសោធន៍ការងារដើម្បីជ្រើសរើសដាក់ក្នុងបញ្ជីសម្រង់ខ្លី (Shortlist) ដើម្បីចូលរួមក្នុងការប្រឡងវិញ្ញាសាសរសេរដូចខាងក្រោម៖

-វិញ្ញាសាចំណេះដឹងទូទៅ ចំណេះដឹងលើវិស័យមនុស្ស និងពន្ធនាគារ............រយៈពេល០១ ម៉ោង ៣០នាទី

-វិញ្ញាសាជំនាញឯកទេស..................................................................................រយៈពេល ០១ ម៉ោង ៣០នាទី

បេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរខាងលើ និងត្រូវអញ្ជើញមកសម្ភាសន៍ផ្ទាល់មាត់ជាដំណាក់កាលចុងក្រោយ។

បេក្ខជនដែលមានបំណងចូលបម្រើការងារត្រូវទៅដាក់ពាក្យសុំចុះឈ្មោះ ដើម្បីចូលរួមប្រឡងប្រជែងជ្រើសរើសនៅ សាលាខេត្តកំពង់ធំ រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ម៉ោង ១៧.០០នាទី នាថ្ងៃសុក្រ ទី១៩ ខែតុលា ឆ្នាំ២០១៨ ជាកាលកំណត់ចុងក្រោយ។

**ឃ-មណ្ឌលប្រឡង និងកាលបរិច្ឆេទប្រឡង**

-មណ្ឌលប្រឡង ៖ខេត្តកំពង់ធំ (បេក្ខជនមកពី ខេត្តកំពង់ធំ សៀមរាប ព្រះវិហារ និងខេត្តឧត្តរមានជ័យ)

-កាលបរិច្ឆេទប្រឡង ៖ ថ្ងៃអាទិត្យ ទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១៨

***បញ្ជាក់***

បេក្ខជនដែលមានជំនាញឯកទេស វេជ្ជបណ្ឌិត និងពេទ្យមធ្យម មកពីខេត្តសៀមរាប និងខេត្តកំពង់ធំ ត្រូវទទួលពាក្យសុំចុះឈ្មោះប្រឡង និងដាក់ពាក្យប្រឡង នៅសាលាខេត្តកំពង់ធំ។

ព័ត៌មានលម្អិត សូមអញ្ជើញទាក់ទងផ្ទាល់ នៅការិយាល័យគ្រប់គ្រងបុគ្គលិក សាលាខេត្តកំពង់ធំ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈ៖

១-លោក **សួត ច័ន្ទតារា** នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស

លេខទូរស័ព្ទ ៖ 077 71 31 71 / 069 65 95 69 ឬ 088 76 00 006

២-លោកស្រី **ភឿន ធារី** ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក

លេខទូរស័ព្ទ ៖ 017 92 18 35 ឬ 016 92 47 20

៣-លោកស្រី **សែន សុភារី** មន្ត្រីការិយាល័យបុគ្គលិក

លេខទូរស័ព្ទ ៖095 83 36 089 ឬ 093 33 61 43។

**អភិបាល**

សុខ-លុ

**ចម្លងជូន÷**

-ក្រសួងមហាផ្ទៃ

-ក្រុមប្រឹក្សាខេត្ត

ដើម្បីជូន "ជ្រាប"

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បី "ជ្រាប"

-មន្ទីរព័ត៌មាន

-គ្រប់សាលាក្រុង- ស្រុក

ដើម្បី "ផ្សព្វផ្សាយ"

-ឯកសារ-កាលប្បវត្តិ

Scanned by CamScanner